# បុណ្យវិសាខបូជា

ថ្វីត្បិតព្រះពុទ្ធ ទ្រង់បរិនិព្វានទៅក៏ពិតមែន ប៉ុន្តែព្រះអង្គទ្រង់បានប្រតិស្ឋានសាសនាគឺពាក្យប្រៀនប្រដៅ ឬធម្មវិន័យសម្រាប់ពុទ្ធមាមកជនគោរពប្រតិបត្ត ដើម្បីស្វែងរកសេចក្តីរំលត់ទុក្ខ។ តាមរយៈព្រះពុទ្ធសាសនា យើងបានយល់ និងប្រតិបត្តបានជាប្រយោជន៍យ៉ាងច្រើននៅក្នុងជីវិតប្រចាំថ្ងៃ។ ទន្ទឹមនឹងនេះ យើងជាពុទ្ធបរិស័ទ ក៏តែងរឭកឃើញដល់គុណូបការៈដ៏ក្រៃលែងរបស់ព្រះអង្គ និងចងចាំនូវព្រឹត្តការណ៍ ឬហេតុដ៏អស្ចារ្យមួយចំនួនធំដែលបានកើតឡើងក្នុងដំណើរនៃជីវិតរបស់ព្រះដ៏មានព្រះភាគ ដែលបង្កើតឡើងនូវថ្ងៃបូជាក្នុងព្រះពុទ្ធសាសនា។ នៅក្នុងព្រះសាសនានេះ មានថ្ងៃបូជាដ៏សំខាន់ជាច្រើនរួមមាន មាឃបូជា វិសាខបូជា អាសាឡ្ហបូជាជាដើម។ បណ្តាថ្ងៃបូជាទាំងនោះ វិសាខបូជាគឺជាពេលវេលាដ៏មានសារៈសំខាន់បំផុតមួយសម្រាប់ពុទ្ធសាសនូបត្ថម្ភក៏គោរពប្រតិបត្តដើម្បីបុណ្យកុសល។ ម្យ៉ាងវិញទៀត ឯកសារមួយចំនួនទាក់ទងនឹងបុណ្យវិសាខបូជានេះ ក៏មិនទាន់សម្បូរបែបនៅឡើយដែរ។ អាស្រ័យហេតុនេះ ដើម្បីជំនួយដល់ការសិក្សាឈ្វេងយល់អំពីបុណ្យវិសាខបូជា ខ្ញុំនឹងប្រមូលស្រាវជ្រាវរៀបរៀងតាមរយៈឯកសារនានា ហើយធ្វើការពន្យល់សេចក្តីឱ្យងាយយល់ដល់អ្នកសិក្សាទូទៅ។

## ១.វិសាខបូជា

### ក. និយមន័យ

**បុណ្យវិសាខបូជា** មកពីពាក្យថា **បុណ្យ** “គុណជាតជាគ្រឿងជម្រះសន្តានចិត្ត, អំពើល្អ” និង**វិសាខ** ឬពិសាខ “ឈ្មោះខែទី៦តាមចន្ទគតិ” ហើយនិង**បូជា** “ការថ្វាយ ឬជូនវត្ថុអ្វីៗចំពោះបូជនីយបុគ្គល” ។ ដូចនេះ បុណ្យវិសាខបូជា ឬវិសាខបូជា (=ពិសាខបូជា) ឈ្មោះពិធីបុណ្យ ឬការធ្វើសក្ការបូជាក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ ។(វចនានុក្រមខ្មែរ)

### ខ. ហេតុនាំឲ្យមានវិសាខបូជា

វិសាខបូជា អាចរាប់ថាជាពិធីបុណ្យដ៏ធំមួយក្នុងចំណោមពិធីបុណ្យធំៗជាច្រើនក្នុងព្រះពុទ្ធសាសនា ពិសេសព្រះពុទ្ធសាសនាថេរវាទ និងជាអភិលក្ខិតសម័យដ៏មានសារៈសំខាន់សម្រាប់ពុទ្ធបរិស័ទទាំងឡាយ ទាំងបព្វជិត ទាំងគ្រហស្ថ គប្បីធ្វើសក្ការបូជាដើម្បីកសាងមហាកុសល ។ ពិធីបុណ្យនេះ ក៏ត្រូវបានទទួលស្គាល់ជាទិវាអន្តរជាតិដោយអង្គការសហប្រជាជាតិនៅក្នុងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩៩ ហើយត្រូវបានប្រារព្ធឡើងជាលក្ខណៈអន្តរជាតិក្នុងទីស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិ និងក្នុងប្រទេសដែលគោរពព្រះ

ពុទ្ធសាសនាថេរវាទជារៀងរាល់ឆ្នាំ ក្នុងថ្ងៃ ១៥ កើត ពេញបូណ៌មី ខែពិសាខ ដើម្បីរំឭកដល់ហេតុសំខាន់ៗ បីយ៉ាងគឺ៖

១) ព្រះពោធិសត្វទ្រង់ប្រសូតចាកគភ៌ព្រះមាតា

២) ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច

៣) ព្រះតថាគតទ្រង់ចូលបរិនិព្វាន ។

ហេតុការណ៍ទាំងបីខាងលើនេះ សុទ្ធតែកើតឡើងក្នុងថ្ងៃ១៥កើត ពេញបូណ៌មី ខែពិសាខ ប្លែកតែឆ្នាំប៉ុណ្ណោះ ។ ព្រោះហេតុនោះហើយ បានជាអ្នកប្រាជ្ញចងក្រងជាគាថាទុកក្នុងគម្ពីរបឋមសម្ពោធិដូច្នេះថា **អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ** ប្រែជាសេចក្តីថា (ព្រះពោធិសត្វ) ចុះកាន់គភ៌ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ទ្រង់ចេញចាកគភ៌ (ប្រសូត) ថ្ងៃពេញបូណ៌មី ខែវិសាខ ព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធក្នុងថ្ងៃពេញបូណ៌មី ខែវិសាខ (ព្រះសម្មាសម្ពុទ្ធ) ទ្រង់បរិនិព្វានក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ ។

## ១.១. ព្រះពោធិសត្វទ្រង់ប្រសូត[១]

មុនពុទ្ធសម័យ ប្រទេសឥណ្ឌា មានឈ្មោះថា **ជម្ពូទ្វីប** ដែលបែងចែកជាពីរផ្នែកគឺ មជ្ឈិមប្រទេស “ផ្នែកខាងក្នុង” និងបច្ចន្តប្បទេស “ផ្នែកខាងក្រៅ” ហើយត្រូវបានចែកជាព្រះរាជាណាចក្រតូចធំជាច្រើន ដែលខ្លះគ្រប់គ្រងដោយមហាក្សត្រ និងខ្លះទៀតគ្រប់គ្រងដោយរាជកុលសម្ពន្ធផ្សេងៗ ។ បណ្តាព្រះរាជាណាចក្រទាំងឡាយនោះ មានព្រះរាជាណាចក្រតូចមួយឈ្មោះថា **កបិលវត្ថុ** ឬ**កបិលព័ស្តុ** ដែលស្ថិតនៅជាប់ជើងភ្នំហិមពាន្ត គ្រប់គ្រង និងដឹកនាំដោយព្រះបាទសុទ្ធោទន៍នៅក្នុងសក្យវង្សគោតមគោត្រ ដែលមានព្រះអគ្គមហេសីព្រះនាមសិរិមហាមាយាដែលជាធីតារបស់ព្រះបាទសុប្បពុទ្ធក្នុងកោលិយវង្សនៃក្រុងទេវទហៈ ។ ព្រះបាទសុទ្ធោទនៈ និងអគ្គមហេសីព្រះអង្គ បានរួមរស់ជាមួយគ្នាយ៉ាងសុខសាន្តក្រោយរាជាអភិសេក ។ ក្នុងរាត្រីមួយ ព្រះនាងមហាមាយា ទ្រង់បានសុបិន្តឃើញហេតុដ៏អស្ចារ្យ គឺឃើញពន្លឺពណ៌សដ៏ចម្លែងចញ្ចេចពីនភាល័យមករកព្រះនាង ហើយក្នុងពន្លឺនោះមានដំរីសម្បុរសក្បុសមានភ្លុក៦ បានធ្វើដំណើរមកកាន់តែជិត

១. ពុទ្ធប្បវត្តិសង្ខេប ទំព័រទី២, ភិក្ខុខន្តិធរោ តាក់ សុខុម, ព.ស. ២២៩៧

ព្រះនាង រួចក៏រលាយចូលក្នុងឧទររបស់ព្រះនាង ។ ព្រះនាង ក៏ទ្រង់ភ្ញាក់អំពីក្រឡាបន្ទំដោយព្រះទ័យត្រេកអរយ៉ាងក្រៃលែង ។ បន្ទាប់អំពីសុបិននិមិត្តនោះមក ព្រះនាងក៏ទ្រង់មានគភ៌ ។

លុះគភ៌គ្រប់១០ខែហើយ ព្រះនាងសិរិមហាមាយាទេវី បានសុំព្រះរាជានុញ្ញាតអំពីព្រះស្វាមីដើម្បីទៅប្រសូតបុត្រនៅក្នុងក្រុងទេវទហៈ ដែលគ្រប់គ្រងដោយព្រះបាទសុប្បពុទ្ធជាបិតារបស់ព្រះនាង (តាមប្រពៃណីឥណ្ឌាបុរាណ) ហើយព្រះបាទសុទ្ធោទន៍ ក៏ទ្រង់រាជានុញ្ញាត ។ ពេលដែលព្រះនាង និងបរិវាររបស់ព្រះនាង ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីដែលអមដំណើរ បានធ្វើដំណើរដល់ឧទ្យានលុម្ពិនី ត្រង់ព្រំប្រទល់រវាងនគរកបិលព័ស្តុ និងនគរទេវទហៈ ក្នុង**ថ្ងៃសុក្រ ១៥ កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំច** មុនពុទ្ធសករាជ៨០ ឆ្នាំ ព្រះនាង ក៏ទ្រង់ប្រសូតព្រះរាជបុត្រនៅក្រោមដើមសាលព្រឹក្ស ដែលមានហ្វូងបក្សីបក្សា និងមធុករបញ្ចេញសំឡេងដ៏ពីរោះជក់ចិត្ត ។ បន្ទាប់អំពីព្រះរាជបុត្រ មានព្រះជន្មបាន៥ថ្ងៃ ព្រះបាទសុទ្ធោទន៍បានអញ្ជើញព្រាហ្មណ៍ ៨ នាក់ ដើម្បីទស្សន៍ទាយលក្ខណៈ និងថ្វាយព្រះនាមដល់ព្រះរាជបុត្រព្រះអង្គ ។ បណ្ដាព្រាហ្មណ៍ ៨ នាក់នោះ ព្រាហ្មណ៍ ៧ នាក់ខាងដើមបានទាយថា **បើព្រះរាជកុមារនៅគ្រប់គ្រងនគរ នឹងបានគ្រងរាជ្យជាស្ដេចចក្រពត្តិប្រកបដោយធម៌ ។ ប្រសិនបើព្រះរាជកុមារចេញសាងព្រះផ្នួស នឹងបានត្រាស់ជាព្រះពុទ្ធ** ។ ដោយឡែក កោណ្ឌញ្ញព្រាហ្មណ៍ ដែលមានវ័យក្មេងជាងគេ បានទាយថា **ព្រះរាជកុមារនេះមិននៅគ្រប់គ្រងនគរទេ ពិតជានឹងត្រាស់ដឹងជាព្រះពុទ្ធប្រាកដ** ។ ព្រាហ្មណ៍ទាំងអស់បានសម្រេចថ្វាយព្រះនាមដល់ព្រះរាជបុត្តថា **សិទ្ធត្ថ** “អ្នកសម្រេចរាល់បំណងទាំងឡាយ” ។

## ១.២. ព្រះពុទ្ធជាម្ចាស់ត្រាស់ដឹងនូវចតុរារិយសច្ច

មុននឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ព្រះសិទ្ធត្ថគោតមដែលបានសាងព្រះផ្នួសហើយ ចាប់ផ្ដើមសាកល្បងតាមវិធីប្រតិបត្តិផ្សេងៗ ។ ឯវិធីទាំងនោះ មានឈានវិធី គឺព្រះអង្គបានចូលទៅសិក្សាក្នុងសំណាក់អាឡារតាបស ចម្រើនបានសម្រេចសមាបត្តិ ៧ និងក្នុងសំណាក់ឧទកតាបស បានសម្រេចសមាបត្តិ ៨។ ប៉ុន្តែព្រះអង្គឈ្វេងយល់ថាឈានវិធីនោះ មិនមែនជាផ្លូវត្រាស់ដឹងពិត ក៏ចាប់យកវិធីមួយទៀតគឺអត្តកិលមថានុយោគ ដែលជាការប្រតិបត្តតាមលំនាំអ្នកបួសផ្សេងៗក្នុងសម័យនោះ ដែលមានលក្ខណៈតឹងរ៉ឹងដូចជា ឈរ ដើរ ឬដេកលើបន្លាជាដើម ហើយដោយពុំទាន់ឃើញការត្រាស់ដឹងពិត ព្រះអង្គក៏បន្ថឹងថែមទៀត ពោលគឺធ្វើទុក្ករកិរិយា ដោយបន្ថយអាហាររហូតដល់លែងឆាន់ចង្ហាន់ទាំងស្រុង ដែលធ្វើឱ្យព្រះអង្គនៅសល់តែស្បែកដណ្ដប់ឆ្អឹង តែនៅមិនបានត្រាស់ ។ ចុងក្រោយ តាមរយៈការពិសោធកន្លងមក ព្រះអង្គ

ទ្រង់យល់ច្បាស់នូវបដិបទាដែលនាំឱ្យត្រាស់ដឹងពិតគឺ **មជ្ឈិមាបដិបទា** គឺសេចក្ដីប្រតិបត្ដយ៉ាងកណ្ដាលពោលគឺអដ្ឋង្គិកមគ្គ ។

បន្ទាប់អំពីនោះមក នៅវេលាព្រឹកមួយ ព្រះអង្គបានទទួលមធុបាយាសពីនាងសុជាតា ហើយក៏ឆាន់ចង្ហាន់នោះ រួចហើយព្រះអង្គ ក៏យាងទៅកាន់ដើមពោធិព្រឹក្សដែលព្រះអង្គបានកំណត់ទុកតាំងពីមុនថាជាកន្លែងសមគួរដល់ការចម្រើនកម្មដ្ឋាន។ ក្នុងដំណើរទៅកាន់ដើមពោធិព្រឹក្សនោះ ព្រះអង្គបានជួបសោត្ថិយព្រាហ្មណ៍ជាអ្នកច្រូតស្មៅស្ពា។ ព្រាហ្មណ៍នោះ ក៏បានថ្វាយស្មៅស្ពាមួយបាច់ដល់ព្រះអង្គដើម្បីក្រាលធ្វើជាបល្ល័ង្ក ។ បន្ទាប់ពីព្រះអង្គបានក្រាលស្មៅស្ពានោះជាបល្ល័ង្កក្រោមដើមពោធិព្រឹក្សរួចហើយ ព្រះអង្គបានគង់លើបល្ល័ង្កនោះ បែរព្រះភក្ត្រទៅទិសខាងកើត ហើយចម្រើនសមាធិកម្មដ្ឋាន ដោយអធិដ្ឋានថា **“អាត្មាអញនឹងមិនក្រោកចេញពីបល្ល័ង្កនេះជាដាច់ខាត លុះត្រាតែអាត្មាអញបានសម្រេចយ៉ាងពិតប្រាកដដល់គោលដៅគឺមោក្ខៈដែលជាការរួចចាកទុក្ខក្នុងវាលវដ្ដសង្សារនៃការកើត ចាស់ ឈឺ ស្លាប់ សម្រាប់ខ្លួនផ្ទាល់ផង និងសម្រាប់មនុស្សសត្វទាំងឡាយផង”** ។ បន្ទាប់មក ព្រះអង្គក៏ទ្រង់ស្រាវជ្រាវរាវរកតទៅទៀត ។ លុះបឋមយាមចូលមកដល់ ព្រះអង្គទ្រង់មានព្រះទ័យបរិសុទ្ធស្អាត ស្ងប់ចាកអារម្មណ៍ទាំងឡាយទាំងពួង បញ្ញាញាណក៏កើតឡើងដល់ព្រះអង្គ។ ព្រះអង្គ ទ្រង់អាចរឭកឃើញនូវអតីតកាលទាំងអស់របស់ព្រះអង្គ និងសព្វសត្វទាំងឡាយ ។ ពេលនោះឯង ព្រះអង្គទ្រង់បានសម្រេចវិជ្ជាមួយគឺ **បុព្វេនិវាសានុស្សតិញ្ញាណ** ។ នៅក្នុងមជ្ឈិមយាម ព្រះអង្គទ្រង់បានសម្រេចវិជ្ជាមួយទៀតគឺ **ចុតូបបាតិញ្ញាណ** ។ ដោយទិព្វចក្ខុ ព្រះអង្គ អាចជ្រាបច្បាស់នូវសត្វច្យុត និងកើតក្នុងទីថោកទាប ឬខ្ពង់ខ្ពស់ ល្អ អាក្រក់ទៅតាមយថាកម្ម ។ លុះដល់បច្ឆិមយាម ព្រះអង្គបានញ៉ាំងញាណឱ្យធ្លាក់ចុះកាន់បដិច្ចសមុប្បាទ ហើយក៏ទ្រង់បានសម្រេចវិជ្ជាទី៣គឺ **អាសវក្ខយញ្ញាណ** គឺការអស់ទៅនៃកិលេសទាំងឡាយទាំងពួង។ ដូចនេះ នៅក្នុងបច្ឆិមយាម គឺពេលជិតភ្លឺនៃរាត្រី **ថ្ងៃ ១៥ កើត ពេញបូណ៌មី ខែពិសាខ** ឆ្នាំរកា ក្នុងព្រះជន្មាយុ ៣៥ ព្រះវស្សា ព្រះអង្គ ក៏បានត្រាស់ដឹងជាព្រះពុទ្ធ គឺឃើញច្បាស់នូវចតុរារិយសច្ចៈ បានដល់ទុក្ខសច្ចៈ ទុក្ខសមុទយសច្ចៈ ទុក្ខនិរោធសច្ចៈ និងទុក្ខនិរោធគាមិនីបដិបទា។

## ១.៣. ព្រះសម្មាសម្ពុទ្ធទ្រង់ចូលបរិនិព្វាន

ក្រោយពេលដែលព្រះអង្គបានត្រាស់ដឹងអស់រយៈពេល ៤៥ ព្រះវស្សាកន្លងមក ព្រះពុទ្ធសាសនាគឺពាក្យប្រៀនរបស់ព្រះដ៏មានព្រះភាគ ក៏រីកសុះសាយយ៉ាងឆាប់រហ័សក្នុងសកលជម្ពូទ្វីប ។ នៅគ្រប់ទីកន្លែង

ឮសូរតែសំឡេងព្រះធម៌ និងការសរសើរគុណព្រះត្រៃរតន៍គឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ ចំពោះកិត្តិគុណរបស់ព្រះអង្គ បើនិយាយដោយសង្ខេបនៅត្រឹមបីយ៉ាងគឺ៖

១. បញ្ញាគុណៈ ព្រះអង្គជាសព្វញ្ញុពុទ្ធ

២. វិសុទ្ធិគុណៈ ព្រះអង្គបរិសុទ្ធដោយការលះបង់កិលេសដាច់ជាសមុច្ឆេទ

៣. ករុណាគុណៈ ព្រះអង្គបរិបូរដោយព្រហ្មវិហារធម៌ និងអប្បមញ្ញាធម៌ចំពោះសព្វសត្វ ។

លុះដល់ថ្ងៃបវារណាចេញវស្សាទី ៤៥ នៅថ្ងៃ ១៥ កើត ពេញបូណ៌មី ខែមាឃ ឆ្នាំម្សាញ់ ព្រះអង្គបានកំណត់ពេលចូលបរិនិព្វាន ដោយព្រះពុទ្ធដីកាចំពោះមារថា **"កន្លងទៅបីខែទៀត តថាគតនឹងចូលបរិនិព្វានហើយ"** ។ បន្ទាប់ពីមហាសន្និបាតដាក់ព្រះជន្មាយុសង្ខាររយៈពេលបីខែមក ព្រះពុទ្ធជាម្ចាស់ជាមួយព្រះអានន្ទ បានយាងទៅកាន់ក្រុងកុសិនារាដែលជារបស់មល្លក្សត្រ។ ព្រះដ៏មានបុណ្យ បានត្រាស់ប្រាប់ព្រះអានន្ទឱ្យរៀបចំគ្រែ ដែលមានក្បាលដំណេកទៅទិសខាងជើង (ព្រះអង្គផ្ទំផ្អៀងទៅខាងស្តាំ ព្រះបាទខាងឆ្វេងត្រួតលើព្រះបាទខាងស្តាំ) ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ថ្វាយព្រះអង្គ។ លុះដល់បច្ឆិមយាម ព្រះអង្គបានត្រាស់ចំពោះភិក្ខុទាំងឡាយថា **"ម្នាលភិក្ខុទាំងឡាយ! ពេលនេះជាឱកាសចុងក្រោយដែលតថាគតផ្តាំអ្នកទាំងឡាយ។ សង្ខារធម៌ទាំងឡាយ មិនទៀងទេ ។ អ្នកទាំងឡាយ ត្រូវផ្តាច់ខ្លួនឱ្យផុតស្រលះអំពីសង្ខារទាំងនោះ។ ចូរអ្នកទាំងឡាយកុំប្រមាថ!"** ។ ព្រះសម្មាសម្ពុទ្ធ មានព្រះពុទ្ធដីកាតែប៉ុណ្ណេះ ទ្រង់ក៏រំលត់ខន្ធចូលកាន់ព្រះនិព្វានជាបរមសុខទៅ នៅក្នុងរាត្រី**ថ្ងៃអង្គារ ១៥កើត ពេញបូណ៌មី ខែវិសាខ** ឆ្នាំម្សាញ់ ក្នុងព្រះជន្មាយុ ៨០ ព្រះវស្សាគត់។ ចង្កៀងដ៏ភ្លឺចញ្ចែង ក៏បានផុតរលត់ទៅ ប៉ុន្តែពន្លឺនៃព្រះធម៌គឺ ព្រះពុទ្ធោវាទ គង់នៅជាធរមានរហូតមក។

## ២. ប្រភពកំណើតនៃវិសាខបូជាក្នុងប្រទេសខ្មែរ[២]

បុណ្យវិសាខបូជា តាមដែលចាស់ទុំ អ្នកមុខអ្នកការទាំងឡាយតំណាលតៗគ្នាបានឱ្យដឹងថា គេបានផ្តើមធ្វើក្នុងរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី "ព្រះអង្គឌួង" ដែលគង់នៅក្នុងក្រុងឧដុង្គជាដំបូង ព្រោះថា កាលក្នុងពុទ្ធសករាជ ២៣៩៧ គ្រិស្តសករាជ ១៨៥៤ សម្តេចព្រះអង្គឌួងទ្រង់សព្វព្រះរាជហឫទ័យយ៉ាងខ្លាំង ហើយបានស្នើសុំទូទៅក្នុងកម្ពុជរដ្ឋ ។

២. កោះសន្តិភាព, ថ្ងៃអង្គារ ទី១៧ ខែឧសភា ឆ្នាំ២០១១ ។

គម្ពីរទី៣ ហៅថា "**បឋមសម្ពោធិកថា**" គឺ បឋមសម្ពោធិវិត្ថារនោះឯង ដែលព្រះឥន្ទមុនី "**ប៉ែន**" គង់នៅវត្តបទុមវតី ទីក្រុងភ្នំពេញ ប្រែ និងរៀបរៀងចេញពីច្បាប់របស់សម្ដេចព្រះមហាសង្ឃរាជ "**សា**" ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ មាន ៣០ បរិច្ឆេទដូចច្បាប់ដើម ។ គម្ពីរនេះមានជាបែបបទសម្រាប់ទេសនា ក្នុងថ្ងៃវិសាខបូជាក្នុងវត្តគណៈធម្មយុត្តិកនិកាយទូទាំងប្រទេសខ្មែរ។ ការធ្វើវិសាខបូជាក្នុងសម័យរជ្ជកាលទី២ នោះប្រហែលជាមានធ្វើតែក្នុងក្រុង មិនទាន់បានផ្សព្វផ្សាយទៅគ្រប់វត្តអារាមនៅឡើយទេ ហើយក៏មិនទាន់មានភាពឱឡារិកអធិកអធមដែរ ។

ពុទ្ធសាសនិកប្រទេសថៃ បានអះអាងថា ប្រពៃណីធ្វើវិសាខបូជាដែលត្រឹមត្រូវតាមលក្ខណៈ កើតមានឡើងតាំងពីត្រឹមរជ្ជកាលទី៤ ដោយព្រះរាជាអង្គនេះជាអ្នកប្រាជ្ញក្នុងផ្លូវព្រះពុទ្ធសាសនា ទ្រង់ចេះគម្ពីរព្រះត្រៃបិដកជ្រៅជ្រះ ទ្រង់បានផ្ដើមធ្វើវិសាខបូជាតាំងពីកាលទ្រង់ព្រះផ្នួសនៅឡើយ ។ លុះដល់ទ្រង់ដាក់ព្រះផ្នួសមកទទួលរាជ្យសម្បត្តិ ក៏ទ្រង់នៅតែបន្តធ្វើវិសាខបូជារៀងដរាបមករហូតដល់ទ្រង់បញ្ជាឱ្យរៀបចំគម្ពីរសម្រាប់ទេសនាក្នុងពិធីបុណ្យនេះ ដូចបានពោលខាងលើ ។ ព្រះមហា **ប៉ាន** គឺសម្ដេចព្រះសុគន្ធាធិបតី ជាគណៈធម្មយុត្តិកនិកាយនៅក្រុងទេព "បាងកក" អំពីព្រះបាទសម្ដេចព្រះចមក្លៅ "**រជ្ជកាលទី៤**" ។ បន្ទាប់មក ក្រោយនោះមួយឆ្នាំ គឺក្នុងពុទ្ធសករាជ ២៣៩៨ ព្រះមហាប៉ាន ទើបនិមន្តមកអំពីក្រុងទេព ព្រះបាទសម្ដេចព្រះហរិរក្ស ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ ហើយបាននិមន្តឱ្យគង់នៅជាចៅអធិការវត្តសាលាគូ ហៅវត្តអម្ពិលបី នៅក្រុងឧដុង្គ តរៀងមក ។ ដោយហេតុថា ព្រះមហាថេរអង្គនេះ កាលដែលលោកគង់នៅទីក្រុងទេពធ្លាប់ធ្វើវិសាខបូជារួចមកហើយ ហើយកាលបានគង់នៅប្រទេសខ្មែរ ព្រមទាំងបានធ្វើជាធំក្នុងគណៈធម្មយុត្តិកនិកាយផង លោកក៏ផ្ដើមឡើងតាមដែលធ្លាប់ធ្វើកន្លងមក។ ប៉ុន្តែយើងពុំបានដឹងច្បាស់ថា នៅពេលដំបូងនោះ តើលោកចាប់ផ្ដើមធ្វើក្នុងឆ្នាំណា សករាជប៉ុន្មាននោះទេ ព្រោះគ្មានឯកសារជាក់ស្ដែង គ្រាន់តែមានសេចក្ដីអះអាងពីអ្នកមុខអ្នកការទាំងឡាយថា ប្រាកដជាមានធ្វើវិសាខបូជា តាំងពីក្នុងពេលដែលលោកគង់នៅក្រុងឧដុង្គមកម្ល៉េះ។ លុះដល់ពេលលោកមកគង់នៅវត្តបទុមវតី ក្រុងភ្នំពេញ ក្នុងពុទ្ធសករាជ ២៤០៨ ក៏បានប្រារព្ធវិសាខបូជារហូតដល់អស់ព្រះជន្ម។ ពិធីវិសាខបូជាត្រូវបានផ្សព្វផ្សាយទូទៅនៅគ្រប់វត្តគណៈធម្មយុត្តិកនិកាយជាប់ជាទំនៀមរហូតមក។ ចំណែកវត្តខាងមហានិកាយ ទើបមានធ្វើក្នុងសម័យក្រុងភ្នំពេញ ក្នុងរជ្ជកាលព្រះស៊ីសុវត្ថិ។ តាមដែលសម្ដេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជ **ជួន ណាត** "កាលនៅជាព្រះសង្ឃនាយក" ដំណាលថា ក្នុងឆ្នាំមួយនោះលោកគ្រូ ព្រះវន្ន័ត ចន្ទ គង់នៅវត្តឧណ្ណាលោម បាននិមន្តទៅក្រុងទេព ឃើញព្រះសង្ឃនៅក្រុងនោះ ទាំងគណៈធម្មយុត្តិកនិកាយ ទាំងគណៈមហានិកាយ ធ្វើវិសាខបូជា ក៏កើតជ្រះថ្លា នៅពេលនិមន្តត្រឡប់មកវិញ បានក្រាបបង្គំទូលសម្ដេចព្រះមហាសង្ឃរាជ "**ជិល ឡៀង**" សុំឱ្យធ្វើ វិសាខបូជា ។ សម្ដេចព្រះមហាសង្ឃរាជទ្បេង ក៏ទ្រង់បាន

ព្រះរាជានុញ្ញាតតាមសំណូមពរ ទើបវិសាខបូជាត្រូវបានធ្វើជាបន្តបន្ទាប់រៀងដរាបមក ។ ប៉ុន្តែពេលនោះក៏ពុំទាន់បានធ្វើគ្រប់វត្តនៅឡើយ គឺមានធ្វើចំពោះតែវត្តនៅក្នុងក្រុង។ ឯវត្តនៅតាមខេត្តក្រៅ មានធ្វើតែតាមវត្តធំៗ ឯវត្តតូចៗ ច្រើនពុំបានធ្វើនៅឡើយ ។ ចំណែកព្រះមហាក្សត្រដែនដី តាំងពីរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្ស "ព្រះអង្គឌួង" មកសុទ្ធតែទ្រង់ជ្រះថ្លាបានទទួលធ្វើគ្រប់ៗព្រះអង្គ ។ តាមឯកសារបានលើកសរសើរព្រះគុណសម្បត្តិព្រះបាទសម្តេចព្រះហរិរក្ស ដែលជាអ្នកផ្តួចផ្តើមធ្វើវិសាខបូជាឡើងជាដំបូង ព្រោះរាជាអង្គនេះ ទ្រង់ធ្លាប់ទៅគង់នៅក្រុងទេព "បាងកក" និងទ្រង់ធ្លាប់សាងព្រះផ្នួសនៅទីនោះ។ ទ្រង់បានសិក្សាព្រះបរិយត្តិធម៌ជ្រួតជ្រាបគម្ពីរព្រះត្រៃបិដកជ្រៅជ្រះ ។ នៅពេលដែលទ្រង់បានឡើងសោយរាជសម្បត្តិ ក៏ទ្រង់ផ្តើមធ្វើពិធីបុណ្យនេះតាមដែលទ្រង់ធ្លាប់បានជ្រួតជ្រាប និងធ្លាប់បានទតឃើញរបៀបបែបផែនដែលគេធ្វើនៅក្រុងទេព ទើបជាប់ជាប្រពៃណីរហូតមកដល់សព្វថ្ងៃ ។

## ៣.របៀបធ្វើវិសាខបូជា

តាមប្រពៃណី ពិធីវិសាខបូជា គេតែងនាំគ្នាធ្វើក្នុងវេលារាត្រី ព្រោះតម្រូវទៅតាមពាក្យថា "បុណ្ណមី" មានសេចក្តីថា ខែពេញបូណ៌មី។ ម្យ៉ាងទៀត ការប្រារព្ធពិធីក្នុងពេលរាត្រី អាស្រ័យដោយលក្ខណៈងាយស្រួល ២ យ៉ាងគឺ ដើម្បីនឹងបានឱកាសអុជគ្រឿងប្រទីប ធូបលា បូជាភ្លើងអគ្គិសនីឱ្យភ្លឺរុងរឿងរន្ទាលច្រាលឆ្អៅ និងដើម្បីបើកឱកាសឱ្យពុទ្ធបរិស័ទបានជួបជុំគ្នាដ៏ច្រើនកុះករទាំងប្រុស ទាំងស្រី អាចបំពេញកុសលកម្មនេះដោយសប្បាយរីករាយ ព្រោះពេលយប់ជាវេលាទំនេរផង។ ជាងនេះទៀត តាមប្រពៃណីនៅក្នុងប្រទេសគោរពព្រះពុទ្ធសាសនាថេរវាទ ពិធីនេះ ក៏ត្រូវបានរៀបចំឱ្យមានការដង្ហែព្រះពុទ្ធប្បដិមា គ្រឿងសក្ការៈផ្សេងៗទៀតផង។

នៅក្នុងដំណើរការនៃកម្មវិធីបុណ្យ ពុទ្ធបរិស័ទតែងនាំគ្នាធ្វើបទនមស្សការព្រះរតនត្រ័យ សមាទានសីល ចម្រើនព្រះបរិត្តសូត្រ ប្រកាសវិសាខបូជា វេរគ្រឿងសក្ការៈដែលបានរៀបចំ ថ្វាយព្រះរតនត្រ័យ និងសម្តែងព្រះធម៌ទេសនា។ បន្ទាប់ពីនោះ តាមទម្លាប់ពីបូរាណ នៅក្នុងវត្តខ្លះក្នុងប្រទេសខ្មែរយើង មានការស្វាធ្យាយ ឬសូធ្យធម៌បទរហូតទល់ភ្លឺក៏មាន។

# វិធីប្រកាសវិសាខបូជា[៣]

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ (៣ដង)**

សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

**សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សព្វទុក្ខស្ស បហានាយ ធម្មំ ទេសេតិ តំ សម្មាសម្ពុទ្ធំ អាទរេន នមស្សាម ។**

ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាស់សម្តែងនូវធម៌ ដើម្បីកម្ចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

**និយ្យានិកោ វត សោ ធម្មោ យោ សព្វទុក្ខស្ស បហានាយ ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ អាទរេន នមស្សាម ។**

ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សម្តែងហើយដោយប្រពៃ ដើម្បីកម្ចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះធម៌នោះ ជាធម៌ស្រោចស្រង់សត្វពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះធម៌នោះ ដោយគោរព។

**សុប្បដិបន្នោ វតស្ស ភគវតោ សោ សាវកសង្ឃោ យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ អាទរេន នមស្សាម ។**

ព្រះអរិយសង្ឃណា លោកប្រតិបត្ត ដើម្បីកម្ចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះអរិយសង្ឃអង្គនោះ ជាសង្ឃសាវ័ក នៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តដោយប្រពៃពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះអរិយសង្ឃអង្គនោះ ដោយគោរព ។ (បន្តទៅ គប្បីធ្វើការប្រកាសវិសាខបូជា)

ថ្ងៃនេះ ជាតិថីពេញបូណ៌មីខែពិសាខ មានព្រះច័ន្ទពេញវង់ ត្រូវនឹងថ្ងៃដែលព្រះសក្យមុនីសម្មា-សម្ពុទ្ធជាបរមគ្រូ ទ្រង់ប្រសូត ទ្រង់បានត្រាស់ដឹងជាសព្វញ្ញុពុទ្ធប្រាកដឡើងក្នុងលោក និងជាថ្ងៃដែលទ្រង់រំលត់ចូលកាន់បរិនិព្វាន តិថីនេះ ជាឧបលក្ខិតសម័យមួយដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ពុទ្ធ-

---

៣. ឯកសារផ្ទៃក្នុងវត្តចាក់អង្រែក្រោម

មាមកជនទាំងបព្វជិត ទាំងគ្រហស្ថ ប្រជុំគ្នាធ្វើសក្ការៈបូជាចំពោះព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ជាបរមពុទ្ធោវាទ និងព្រះអរិយសង្ឃ ជាសាវ័ករបស់ព្រះអង្គ។

ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកជួបជុំគ្នា រៀបចំគ្រឿងសក្ការបូជា មានទៀនធូប និងភ្ញីផ្កាជាដើម តម្កល់ទុកក្នុងទីនេះ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គគង់នៅជាប្រធាន ហាក់ដូចជាព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចយាងមកគង់ក្នុងទីចំពោះមុខនៃយើងទាំងអស់គ្នា។

យើងខ្ញុំព្រះអង្គទាំងឡាយ សូមថ្វាយនូវគ្រឿងសក្ការបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យទាំងបី ដោយសេចក្តីគោរព។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គលរបស់ទេវតា និងមនុស្សក្នុងលោក ឥតមានបុគ្គលណាមួយ ផ្ទឹមស្មើនឹងព្រះអង្គឡើយ ទោះបីព្រះអង្គទ្រង់ចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយ អស់កាលយូរអង្វែងទៅហើយក៏ពិតមែន ប៉ុន្តែទ្រង់បានប្រតិស្ថានព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យដ៏បរិសុទ្ធវិសេសទុកជាតំណាងព្រះអង្គ ព្រះគុណរបស់ព្រះអង្គក៏នៅមានប្រាកដ ទាំងព្រះបរមសារីរិកធាតុ និងព្រះពុទ្ធរូបស្នងព្រះអង្គ ក៏នៅមានប្រាកដដែរ សូមព្រះដ៏មានបុណ្យ ជាបរមសាស្តាទ្រង់ព្រះមេត្តាប្រោសទទួលនូវគ្រឿងសក្ការបូជារបស់យើងខ្ញុំព្រះអង្គ ដែលរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្សឱ្យយើងខ្ញុំព្រះអង្គបានប្រាកដ ដោយឥដ្ឋមនុញ្ញផលវិបុលសុខ និងសេចក្តីចម្រើនដ៏ធំទូលាយ អស់កាលជាយូរអង្វែងទៅហោង ។(ចប់ពិធីប្រកាសវិសាខបូជា)

## បេរគ្រឿងសក្ការវិសាខបូជា

អជ្ជាយំ ភន្តេ វិសាខបុណ្ណមីកាលោ សម្បត្តោ តស្ស អម្ហាកំ ភគវតោ តក្កាលសទិសេន នក្ខត្តេន យុត្តោ ចាតុកវិ ។ តថា ហិ ខោ អម្ហាកំ លោក-នាយកោ សោណសំវច្ឆរេ វិសាខបុណ្ណមិយំ សុក្រវារេ គព្ភាភិក្ខមនំ បត្វា ច កុក្កុដេ វិសាខបុណ្ណមិយំ ពុធវារស្មឹ សព្វញ្ញុតំ បត្វា ច សប្បេ វិសាខបុណ្ណមិយំ អង្គារេ បរិនិព្វានំ បត្វា ច អហោសិ, តស្មា មយំ សព្វេ តំ តំ តស្ស នក្ខត្តសមយំ អនុស្សរន្តា ឥធ សមាគតា ឥមេហិ ទីបធូបមាលាទីហិ សក្ការេហិ ច បូជំ ករោម ធម្មេហិ ច, សាធុ ភន្តេ ភគវា សុចិរប្បរិនិព្វុតោបិ ឥមេ អម្ហាកំ ឧក្កត-

បណ្ណាការភូតេ បដិគ្គណ្ហាតុ សាសនស្ស ចិរដ្ឋាយ ចេវ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ប្រែថា បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន កាលឥឡូវនេះជាថ្ងៃពេញបូណ៌មី ខែវិសាខមកដល់ហើយ ប្រកបដោយនក្ខត្តសម័យ ដូចកាលសម័យរបស់ព្រះដ៏មានព្រះភាគជាម្ចាស់នៃយើងនោះប្រាកដ។ ត្បិតថា ព្រះលោកនាយក ជាអម្ចាស់នៃយើង កាលទ្រង់ប្រសូតចាកគភ៌ព្រះមាតា ក្នុងថ្ងៃសុក្រ ពេញបូណ៌មី ខែពិសាខ ឆ្នាំចនោះក្តី បានត្រាស់ដឹងសព្វញ្ញុតញ្ញាណ ក្នុងថ្ងៃពុធ ពេញបូណ៌មី ខែពិសាខ ឆ្នាំរកានោះក្តី ទ្រង់បរិនិព្វានក្នុងថ្ងៃអង្គារ ពេញបូណ៌មី ខែវិសាខ ឆ្នាំម្សាញ់នោះក្តី មានហើយដោយពិត។ ព្រោះហេតុនោះ (កាលឥឡូវនេះ) យើងខ្ញុំទាំងឡាយបានរឭកឃើញនូវនក្ខត្តសម័យនោះៗរបស់ព្រះអង្គ ទើបនាំគ្នាមកជួបជុំក្នុងទីនេះ ធ្វើបូជានូវគ្រឿងសក្ការបូជាផ្សេងៗ មានប្រទីប ទៀន ធូប និងកម្រងផ្កាជាដើមផង និងបូជាដោយធម៌ផង បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានអស់កាលជាយូរអង្វែងទៅហើយក្តី សូមព្រះអង្គទទួលយកនូវគ្រឿងបណ្ណាការទាំងនេះ ដែលជាទុគ្គតបណ្ណាការរបស់យើងខ្ញុំព្រះអង្គទាំងឡាយ ដើម្បីធ្វើឱ្យសាសនារុងរឿងស្ថិតស្ថេរចីរកាលបានយូរអង្វែងទៅផង ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង។

## ៤. គោលបំណងនៃការប្រារព្ធវិសាខបូជា

គោលបំណងនៃពុទ្ធបរិស័ទ ដែលតែងប្រារព្ធធ្វើពិសាខបូជានោះ មានដូចតទៅ៖

- សម្តែងនូវកតញ្ញូកតវេទិតា ចំពោះព្រះសម្មាសម្ពុទ្ធ ក្នុងនាមជាពុទ្ធបរិស័ទ ។ អាស្រ័យដោយមានការប្រសូតឡើងនៃព្រះពោធិសត្វ ទើបយើងបានស្គាល់ព្រះពុទ្ធសាសនា ។
- រឭកដល់សេចក្តីត្រាស់ដឹងរបស់ព្រះដ៏មានប្រភាគ ពោលគឺអរិយសច្ចៈទាំងបួន ដែលជាត្រីវិស័យមួយដ៏មានប្រសិទ្ធភាពសម្រាប់ជីវិតរបស់មនុស្សទូទៅ ។
- ការអប់រំចិត្ត ព្រោះធម្មតា មនុស្សទូទៅ ពេលមាននរណាម្នាក់ដែលជាទីស្រឡាញ់ស្លាប់ តែងយំរៀបរាប់ដោយប្រការផ្សេងៗ ប្រកបដោយសេចក្តីទុក្ខសោក ។ ផ្ទុយទៅវិញ ព្រះសម្មាសម្ពុទ្ធរមែងដាស់តឿនពុទ្ធបរិស័ទឱ្យភ្ញាក់រឭក ពិចារណាសង្ខារធម៌ ជៀសវាងសេចក្តីសោកគ្របសង្កត់ ទោះបីជាព្រះអង្គទ្រង់ចូលបរិនិព្វានក៏ដោយ ដូចព្រះពុទ្ធោវាទចុងក្រោយរបស់ព្រះអង្គ គឺទូន្មានសាវ័កព្រះអង្គកុំ

ឱ្យមានបមាទធម៌ (ធ្វេសប្រហែស)។ ម្យ៉ាងទៀត ព្រះពុទ្ធបរិនិព្វានក៏ពិតមែន តែព្រះធម្មវិន័យគឺព្រះពុទ្ធសាសនាស្ថិតនៅដល់សព្វថ្ងៃ ។ ប្រសិនបើយើងសិក្សា និងប្រតិបត្តឱ្យ ជាក់ច្បាស់ក្នុងធម៌ ទុកដូចជាយើងបានកើតទាន់ព្រះពុទ្ធគង់នៅ សមដូចពុទ្ធដីកាថា "**យោ មំ បស្សតិ សោ ធម្មំ បស្សតិ, យោ ធម្មំ បស្សតិ សោ មំ បស្សតិ**" (ប្រែថា) "បុគ្គលណាឃើញតថាគត បុគ្គលនោះឈ្មោះថាឃើញធម៌, បុគ្គលណាឃើញធម៌ បុគ្គលនោះឈ្មោះថាឃើញតថាគត" ។

## ៥. ប្រយោជន៍នៃបុណ្យវិសាខបូជា

បុណ្យវិសាខបូជា គឺជាឱកាសសម្រាប់ពុទ្ធបរិស័ទកសាងមហាកុសលសម្រាប់ខ្លួនដោយអាមិសបូជា និងបដិបត្តិបូជា។ ព្រោះថា ក្រៅពីការថ្វាយគ្រឿងសក្ការៈចំពោះព្រះរតនត្រ័យ និងប្រគេនទេយ្យទានដល់ព្រះសង្ឃជាស្រែបុណ្យ ក៏ជាពេលសម្រាប់រក្សាសីល ស្តាប់ព្រះធម្មទេសនា ធម្មសាកច្ឆា ដែលជាការប្រព្រឹត្តទៅក្នុងត្រៃសិក្ខាគឺ សីល សមាធិ បញ្ញា ។ ជាងនេះទៀត ពិធីនេះ ក៏ជាវេលាប្រកបដោយខ្លឹមសារគឺការរក្សានូវប្រពៃណីព្រះពុទ្ធសាសនាផង ប្រមូលបុណ្យកុសលឧទ្ទិសជូនបុព្វការីជនដែលបានធ្វើមរណកាលទៅផង។

## ៦. ឯកសារយោង


១. វចនានុក្រមខ្មែរ

២. ពុទ្ធប្បវត្តិសង្ខេប, ភិក្ខុខន្តិធរោ តាក់ សុខុម, ព.ស. ២៥៥៧

៣. សារព័ត៌មានកោះសន្តិភាព ចុះផ្សាយថ្ងៃអង្គារ ខែឧសភា ឆ្នាំ២០១១

៤. ឯកសារផ្ទៃក្នុងវត្តចាក់អង្រែក្រោម, រាជធានីភ្នំពេញ